**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខៈ ០៤១៤/២០ ក.អ.ជ

ថ្ងៃចន្ទ ១០កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ ២០២០
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

ក្នុងខែឧសភា ឆ្នាំ២០២០ នៅក្នុងពិភពលោក ក៏ដូចជានៅក្នុងតំបន់ដែរ ជម្ងឺកូវីដ១៩ នៅតែបន្តរាតត្បាតនៅឡើយដោយពុំមានថ្នាំវ៉ាក់សាំងការពារនោះទេ ។ ដោយឡែកនៅប្រទេសកម្ពុជា ទោះបីជម្ងឺកូវីដ១៩ មានស្ថានភាពធូរស្រាលយ៉ាងណាក៏ដោយក៏រាជរដ្ឋាភិបាលកម្ពុជានៅបន្តរឹតបន្តឹងឲ្យអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាលដដែល ។ សកម្មភាពសេដ្ឋកិច្ចខ្នាតតូចៗ តំបន់ទេសចរណ៍ក្នុងប្រទេសបានដំណើរការបើកអាជីវកម្មបណ្តើរហើយៗ ដើម្បីដោះស្រាយបញ្ហាជីវភាពរស់នៅតាមគ្រួសារក្នុងសហគមន៍ជនបទ ទីប្រជុំជន ក៏ដូចជាទីក្រុងដែរ ។ ចំពោះកិច្ចដំណើរការអភិវឌ្ឍន៍ជនបទ ក្រសួងបានបន្តរក្សានិរន្តរភាពការងារ ដោយគោរពតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលដដែល ។

ការកសាង ស្តាបនា ជួសជុលលើកកម្រិតផ្លូវថ្នល់ជនបទ ទឹកស្អាត អនាម័យជនបទ និងផ្នែកផ្សេងៗទៀតនៅរក្សាបន្តសកម្មភាព លើកលែងតែការប្រជុំ សិក្ខាសាលាធំៗត្រូវបានបន្តផ្អាកដំណើរការដដែល ។ ដៃគូអនុវត្តគម្រោងជាទ្វេរភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលនៅបន្ត សកម្មភាពធម្មតាតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

លទ្ធផលដែលក្រសួងសម្រេចបានប្រចាំខែឧសភា ឆ្នាំ២០២០ នេះមានដូចខាងក្រោមៈ

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ការអនុវត្តផែនការសកម្មភាពក្នុងវិស័យអភិវឌ្ឍន៍ជនបទទាំងមូលសម្រេចបានប្រមាណជាង ៣៥% នៃផែនការសកម្មភាពប្រចាំឆ្នាំ ២០២០ គិតមកដល់ខែឧសភានេះ ។

### ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

#### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែឧសភា ឆ្នាំ២០២០ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៥២៨ នាក់ (ស្រី ៤១១ នាក់) ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែមេសា គឺមានការថយចុះ


អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

ចំនួន ០១ នាក់ ដោយសារចូលនិវត្តន៍។ ក្រសួងបានទទួលលិខិតចូលចំនួន ១០៦ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១១៤ ច្បាប់ ចុះលេខប្រកាស និងសេចក្ដីសម្រេចនានាចំនួន ១៤ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ១៦៦ ច្បាប់ ។

**២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

ក្នុងខែឧសភា នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២០ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ២ ៤៨៣ ៨៨៧ ៧៥០ រៀល ស្មើនឹង១,៧៤% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ១១ ២៥០ ៧១០ ០០០ រៀល ស្មើនឹង ៥,៩២% នៃច្បាប់ថវិកា ។

**២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- បន្តរៀបចំផែនការកែទម្រង់ហិរញ្ញវត្ថុសាធារណៈលម្អិតតាមខែនីមួយៗដើម្បីតាមដានការអនុវត្តសូចនាករសមិទ្ធិកម្មគន្លឹះ
- បន្តរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ និងត្រៀមរៀបចំផែនការថវិកាឆ្នាំ ២០២១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធអនឡាញ។

**២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ**

- រៀបចំផ្ទេរមុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ០៣ ដោយប្រគល់ទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងព្រះរាជាណាចក្រកម្ពុជាចាប់ពី ឆ្នាំ២០២០ តទៅ ។

**២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ**

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្ដល់លិខិតគាំទ្រសុំអន្តរាគមន៍ដើម្បីសុំចុះបញ្ជីស្លាកលេខ ONG សម្រាប់រថយន្តចំនួន ០៣ គ្រឿង របស់អង្គការហ្វូដណេបឺសកម្ពុជា និងអង្គការទស្សនៈពិភពលោក
- បានធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងគម្រោង រវាងក្រសួងអភិវឌ្ឍន៍ជនបទ និង អង្គការ អាយ ឌី អ៊ី
- រៀបចំតារាងតាមដានការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីតាមខែនីមួយៗ ។

**២.២.៦. ការងារអធិការកិច្ច និងសវនកម្ម**

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៩-២០២០ និងចុះពិនិត្យជាក់ស្ដែងការងារសាងសង់ ជួសជុលអណ្ដូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០៣ រួមមាន ខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។

**២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍**

- គម្រោងថែទាំខួប ឆ្នាំ ២០២០ សរុបចំនួន ៣០ គម្រោង ស្មើនឹង ៥៧ ខ្សែ ប្រវែងសរុប ៤៦៣,៤២ គ.ម លូមូល ៦០ កន្លែង និងលូប្រអប់ ០២ កន្លែង សម្រេចលទ្ធផលគិតជាមធ្យមបាន ១០%
- គម្រោងថែទាំប្រចាំ ឆ្នាំ ២០២០ សរុបចំនួន ៣៨ គម្រោង ស្មើនឹង ២៩៨ ខ្សែ ប្រវែងសរុប ២ ៨១៣,៧៤ គ.ម លូមូល ០១ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ២ ១៥២ ស្លាក សម្រេចលទ្ធផលគិតជាមធ្យមបាន ១០%
- ការងារស្តាបនា កែលម្អ និងជួសជុល ឆ្នាំ ២០២០ មាន ៩៧ គម្រោង ប្រវែងសរុប ៧២៤,៩១ គ.ម សម្រេចបានលទ្ធផលជាមធ្យម ៣៥,៤៣ %។

**២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ**

- សាងសង់អណ្តូងអាហ្វ្រីដេវ ចំនួន ០២ អណ្តូង នៅខេត្តក្រចេះ
- សាងសង់អាងត្រងទឹកភ្លៀងចំនួន ០៨ អាង នៅខេត្តប៉ៃលិន សម្រេចបាន ២០%
- ជួសជុលអណ្តូងស្នប់ និងអណ្តូងអាហ្វ្រីដេវ ចំនួន ៧១ អណ្តូង នៅខេត្តកំពង់ឆ្នាំង ក្រចេះ ស្ទឹងត្រែង រតនគិរី ប៉ៃលិន និងខេត្តព្រះសីហនុ ។

**២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- បានបន្តយុទ្ធនាការផ្សព្វផ្សាយវិធានការការពារទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩ នៅស្រុកកងមាស ខេត្តកំពង់ចាម ដោយបានប្រគល់ជូននូវសម្ភារមួយចំនួនទៅរដ្ឋបាលឃុំទាំង ១១ ក្នុងមួយឃុំទទួលបានអាល់កុល ១០ លីត្រ ម៉ាស់ ០២ ប្រអប់ សាប៊ូ ២៧០ ដុំ និងផ្ទាំងរូបភាពអប់រំចំនួន ០៣ មុខ ដោយមួយមុខមានចំនួន ៩៣០ សន្លឹក និងថវិកាមួយចំនួនសម្រាប់បន្តផ្សព្វផ្សាយនៅតាមមូលដ្ឋានរបស់ខ្លួន ដោយមានការគាំទ្រពីក្រុមប្រឹក្សាសហប្រតិបត្តិការវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៃអង្គការសហប្រជាជាតិ
- បានបន្តចុះផ្សព្វផ្សាយប្រជាពលរដ្ឋអោយប្រតិបត្តិអនាម័យល្អនៅតាមគ្រួសារក្នុងខេត្តគោលដៅទាំង១៣ រួមមានខេត្តកោះកុង កែប ព្រះសីហនុ កំពង់ស្ពឺ កំពង់ឆ្នាំង ប៉ៃលិន សៀមរាប ឧត្តរមានជ័យ ក្រចេះ កំពង់ចាម ត្បូងឃ្មុំ ព្រះវិហារ និងខេត្តស្វាយរៀង ។

**២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍**

- រៀបចំមេរៀនសម្រាប់ការអប់រំក្រៅប្រព័ន្ធ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០ ។

**២.២.១១. ការងារបណ្តុះបណ្តាល**

- បានរៀបចំចងក្រងបញ្ជីសំនួរស្តីពីតម្រូវការរបស់ការិយាល័យបណ្តុះបណ្តាល នៅតាមមន្ទីរអភិវឌ្ឍន៍ជនបទទាំង២៥ រាជធានី-ខេត្ត
- បានរៀបចំគ្រោងមេរៀន ស្តីពីតួនាទី និងភារកិច្ចរបស់ជនបង្គោលការិយាល័យបណ្តុះបណ្តាល នៅតាមអង្គភាពក្រោមឱវាទក្រសួង

- បានរៀបចំធ្វើបច្ចុប្បន្នភាពទិន្នន័យបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១២ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ឆ្នាំ២០២០ ប៉ុន្តែដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩ មជ្ឈមណ្ឌលបានសម្រេចចិត្តផ្អាកជាបណ្តោះអាសន្នលើការបណ្តុះបណ្តាល រង់ចាំដល់មានការធូរស្រាលនៃជម្ងឺកូវីដ១៩ ។

**២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

- គិតត្រឹមថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៤ ១៤៥ ៣១៤ ៧៣៥ រៀល (បួនបីលានមួយរយសែសិបប្រាំលានបីរយដប់បួនពាន់ប្រាំពីររយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៥៥ ៥៥៤ ,៦៤ ដុល្លារអាមេរិក (មួយលានហាសិបប្រាំពាន់ប្រាំរយហាសិបបួនដុល្លារនិងហុកសិបបួនសេន) (១USD=៤000រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ០៦៩ នាក់ នៅភូមិគោលដៅចំនួន ១៩២ ភូមិ ៧៤ ឃុំ ៣៣ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានចុះសិក្សា និងរៀបចំទីតាំងសម្រាប់ការតាំងពិព័រណ៍ផលិតផលជនបទ និងសហគមន៍ នៅខេត្តកំពង់ឆ្នាំង ។

**២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- ប្រជុំពិភាក្សាទៅលើការពិនិត្យឡើងវិញលើរបាយការណ៍ជាតិ ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គមសេដ្ឋកិច្ច របស់ជនជាតិដើមភាគតិចនៅកម្ពុជា ជាមួយអង្គការ CIPO
- ប្រជុំពិភាក្សា ស្តីពីផែនការយុទ្ធសាស្ត្រ អភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ជាមួយអង្គការ NGO FORUM ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**

ក្នុងខែឧសភា ឆ្នាំ ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំនួន ០១ ករណី ។

**២.២.១៥. ការងារយេនឌ័រ**

- ចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការតាមដាន និងវាយតម្លៃការអនុវត្តអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ី-ដ)
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២០ ។

## ២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី

### ២.៣.១. គម្រោងកែលម្អផ្លូវជនបទ ដំហាន ២

គិតត្រឹមដំណាច់ខែឧសភានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៧៤,៣៦%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៧៨,៩៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៦៩,៦៤%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៨១,៦៦%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៨៧,៦៨%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១២៥,៥០ គ.ម សម្រេចបាន ១០០%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ ខ្សែ មានប្រវែងសរុប ១០១,២០ គ.ម សម្រេចបាន ១០០%
- ខេត្តបន្ទាយមានជ័យ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ១០០%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ ខ្សែ មានប្រវែងសរុប ៥០ គ.ម សម្រេចបាន ១០០%
- សាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម សម្រេចបាន ១០០ % ។

### ២.៣.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ

គិតត្រឹមខែឧសភានេះ គម្រោងបាន និងកំពុងអនុវត្តចំនួន ៦៤ គម្រោង ប្រវែង ១៧៣ ៨២៤ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១២ ក្នុងនោះបានបញ្ចប់ការងារ បានចំនួន ០៦ គម្រោង ប្រវែងសរុប ១២ ៣១៤ ម៉ែត្រ នៅខេត្តកណ្ដាល ខេត្តកំពង់ធំ និងខេត្តតាកែវ ។

### ២.៣.៣.គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង ( Mekong Lancang Cooperation )

- ពុំមានសកម្មភាព ។

### ២.៣.៤. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា

- ពុំមានសកម្មភាព ។

### ២.៣.៥. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍

គិតត្រឹមខែឧសភានេះ គម្រោងសម្រេចបាន ៖

- បាន និងកំពុងសាងសង់ផ្លូវ ចំនួន ០៧ ខ្សែ ប្រវែង ៤៩,៨៩គីឡូម៉ែត្រ នៅខេត្តកណ្តាល ដោយសម្រេចបាន ៦%
- បាន និងកំពុងធ្វើការវាយតម្លៃឯកសារដេញថ្លៃ កញ្ចប់ទី២ សម្រាប់ការស្តាបនាផ្លូវប្រវែង ៤៥ គីឡូម៉ែត្រនៅក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង
- បានធ្វើការផ្សព្វផ្សាយការដេញថ្លៃកញ្ចប់ទី៣ សម្រាប់ការស្តាបនាផ្លូវប្រវែង ១៦០ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង
- កំពុងរៀបចំឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការងារ Road Asset Inventory System ។

### ២.៣.៦. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ជំហាន ២

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ជំហាន២ អនុវត្តរយៈពេល ១២ខែ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលក្នុងនោះគម្រោងផ្គត់ផ្គង់ទឹកជនបទអនុវត្តនៅខេត្តគោលដៅចំនួន ១០ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង ព្រៃវែង កំពត ស្វាយរៀង កំពង់ស្ពឺ និងខេត្តកំពង់ចាម និងគម្រោងកែលម្អផ្លូវជនបទ ជំហាន ២ អនុវត្តនៅខេត្តគោលដៅចំនួន ០៦ រួមមាន ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តត្បូងឃ្មុំ ។ នៅក្នុងខែឧសភានេះ គម្រោងសម្រេចបាន៖

- ជីកអណ្តូងបានចំនួន ៦៣ អណ្តូង
- តំឡើងស្នប់បានចំនួន ១៤៦ ស្នប់
- ជីកស្រះធម្មតា និងស្រះមានរៀបថ្ម ចំនួន ០៨ ស្រះ
- បាន និងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ១១៩,៥៥ គ.ម នៅខេត្តគោលដៅទាំង ០៦ សម្រេចបាន ១៥ % ។

### ២.៣.៧. គម្រោងពិពិធកម្មកសិកម្មកម្ពុជា

គម្រោងពិពិធកម្មកសិកម្មកម្ពុជាអនុវត្តរយៈពេល ០៦ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ។ គម្រោងមានគោលបំណង ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍខ្សែច្រវ៉ាក់ផលិតផលកសិកម្មចម្រុះ នៅក្នុងតំបន់ភូមិសាស្ត្រ នៅខេត្តគោលដៅចំនួន ១៣ រួមមាន ខេត្តត្បូងឃ្មុំ កណ្តាល បាត់ដំបង កំពង់ចាម កំពង់ស្ពឺ សៀមរាប ព្រះវិហារ មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី ក្រចេះ កំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ នៅក្នុងខែឧសភានេះគម្រោងសម្រេចបាន ៖

- កំពុងដំណើរការជ្រើសរើសក្រុមទីប្រឹក្សាបច្ចេកទេស (ជ្រើសរើសទីប្រឹក្សាបច្ចេកទេសផ្នែកលទ្ធកម្ម និងហិរញ្ញវត្ថុ)

- បានបើកកិច្ចប្រជុំ ស្តីពីផែនការថវិកាប្រចាំឆ្នាំ ជាមួយអន្តរក្រសួង និងធនាគារពិភពលោក ដើម្បីពិភាក្សាលើការអនុវត្តការងារបន្ត និងកំណត់លើផែនការថវិកាប្រចាំឆ្នាំ
- បានរៀបចំនីតិវិធីលទ្ធកម្មគម្រោង ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- ពន្យាពេលពិភាក្សាការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០២១-២០២៣ ដោយសារបញ្ហាជម្ងឺកូវីដ១៩
- គម្រោងសាងសង់មួយចំនួនមិនអាចបញ្ចប់តាមការគ្រោងទុកដោយសារបញ្ហាជម្ងឺកូវីដ១៩
- ខ្វះយន្តការគាំទ្រ និងការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ
- ទាមទារពេលវេលាវែង ដើម្បីជំរុញការផ្លាស់ប្តូរទម្លាប់របស់ប្រជាជន ក្នុងការប្រតិបត្តិអនាម័យល្អ
- សមត្ថភាពចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- តំបន់ខ្លះខ្វះទឹកដែលអាចប៉ះពាល់ដល់ស្ថានភាពអនាម័យ
- ទម្លាប់សង្គមក្នុងការបន្ទោរបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមួយចំនួនមានជីវភាពខ្វះខាត ជាហេតុនាំឲ្យមានការធ្វើចំណាកស្រុកទៅប្រកបមុខរបរនៅប្រទេសជិតខាង ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួន
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ
- កិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត នៅមានកម្រិតនៅឡើយលើវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ ។

### ៣.២. ទិសដៅតាមអង្គភាព

- បន្តរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០២១-២០២៣ និងថវិកាកម្មវិធីឆ្នាំ ២០២១ ពីចម្ងាយ (តាមប្រព័ន្ធអនឡាញ)
- បន្តចុះតាមដានការអនុវត្តផែនការឆ្នាំ ២០២០ តាមអង្គភាពថវិកា
- ចុះតាមដានសកម្មភាពអង្គការមិនមែនរដ្ឋាភិបាល
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តជម្រុញការងារតាមការដ្ឋានសាងសង់ផ្លូវ ដើម្បីបញ្ចប់ការងារឲ្យបានទាន់ពេលវេលា

- បន្តចុះត្រួតពិនិត្យការងារស្ថាបនា និងកែលម្អផ្លូវជនបទ
- អនុវត្តការងារថែទាំ និងជួសជុលផ្លូវនៅតាមបណ្តាខេត្ត
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានី ខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការ និងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្ត គោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- សិក្សាស្រុកគោលដៅថ្មី និងរៀបចំឯកសារគតិយុត្តិសម្រាប់ស្រុកចំនួន ១៥ ដែលត្រូវសាកល្បងផ្ទេរមុខងារអនាម័យ
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិ ជំហានទី ១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី ២ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- ពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- សិក្សាភូមិគោលដៅដើម្បីរៀបចំកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ញាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

ឥទ្ធិពលនៃជម្ងឺកូវីដ១៩ នៅតែបន្តរាតត្បាតជាសកល ជាហេតុធ្វើឲ្យសកម្មភាពអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច និងវប្បធម៌ត្រូវបានបន្តកាត់បន្ថយជាច្រើន ដែលបានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួង ។

ក្នុងខែឧសភានេះ លទ្ធផលជាទូទៅ ក្រសួងសម្រេចបាននៅមានកម្រិតទាបជាងផែនការដដែល ដោយសារឥទ្ធិពលនៃជម្ងឺកូវីដ១៩ ក្រសួងនៅតែបន្តចូលរួមក្នុងការទប់ស្កាត់ការចម្លងជម្ងឺកូវីដ១៩ ក្នុងសហគមន៍ជនបទតាមរយៈការអប់រំផ្សព្វផ្សាយអនាម័យជនបទនៅទូទាំងប្រទេសជាមួយដៃគូ និងស្ថាប័នផ្សេងៗទៀតទទួលបានលទ្ធផលល្អប្រសើរ ។ ការងារស្ថាបនាសាងសង់ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធជនបទមានសកម្មភាពធម្មតា ពិសេសគម្រោងកិច្ចសហប្រត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា នៅ

រក្សាការងារប្រកបដោយនិរន្តរភាព ។ ក្រសួងកំពុងរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៣ និងផែនការថវិកាឆ្នាំ ២០២១ តាមប្រព័ន្ធអនឡាញដើម្បីត្រៀមចរចារកញ្ចប់ថវិកានៅពេលខាងមុខនេះ ឲ្យទទួលបានជោគជ័យ ។

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**